# តស៊ូ

១. ជីវិតកម្មករគឺការត...ស៊ូ យើងខំប្រឹងធ្វើការរាល់ថ្ងៃ
នាយទុនកេងប្រវ័ញ្ច បំបិទសិទ្ធិសេរី កម្មករប្រុសស្រីឈឺចាប់។

២. មកពួកយើងមករួមគ្នាត...ស៊ូ មកពួកយើងមករួមកំលាំង
ទុក្ខលំបាកយ៉ាងណាក៏យើងនៅតែប្រឆាំង កំហឹងឆេះដំក្នុងចិត្ត។

បន្ទរ ត្រូវពុះពា ទោះមានភ្នំ សមុទ្រ ដើរជាក្បួនរួមគ្នា និងការតស៊ូ គ្រប់ពេលវេលា
សាមគ្គីឈ្នះមិនខាន។

៣. ពាក្យចាស់ថា ចង្កឹះមួយបាច់ កាច់មិនងាយបាក់ឡើយ
ជ័យជំនះមិនដែលបានដោយងាយឡើង កម្មករអើយតស៊ូ។

បន្ទរ នៅទីណា មានការជិះជាន់ កម្មករត្រូវក្រោកឡើង តបតប្រឆាំងគ្រប់ពេលវេលា
សាមគ្គីឈ្នះមិនខាន។

៤. ពាក្យចាស់ថា ចង្កឹះមួយបាច់ កាច់មិនងាយបាក់ឡើយ
ជ័យជំនះមិនដែលបានដោយងាយឡើង កម្មករអើយតស៊ូ។

និពន្ធដោយៈ ក្រុមតន្ត្រីយុវវ័យនាំសារ
ច្រៀងដោយៈ ក្រុមតន្ត្រីយុវវ័យនាំសារ
រក្សាសិទ្ធដោយ កម្មវិធីស្ត្រីដើម្បីការផ្លាស់ប្តូរ, ២០០៦, ព្រះរាជាណាចក្រកម្ពុជា